១- លោក **គុង លុកសេន** (KONG LOOK SEN) ហៅ KWONG LOCK KING សញ្ជាតិសិង្ហបុរី កើតថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៣៦ នៅ PERAK ប្រទេសម៉ាឡេស៊ី

២- អ្នកស្រី **ស៊ូ លីអេង** (SOO LEE ENG) (ភរិយា) សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៤០ នៅ PERAK ប្រទេសម៉ាឡេស៊ី ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

===

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ៤៣ អនក្រ.បក

## ស្តីពី

## ការបង្កើត និង ការប្រព្រឹត្តិទៅនៃ លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រេច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

យោងតាមសំណើរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម លេខ ៧០ ឧក្រច ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០១

**សំរេច**

**មាត្រា ១.-** ត្រូវបានបង្កើតលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អោយទទួលបន្ទុករៀបចំចាត់ចែងការងារធ្វើកំណត់ហេតុ ធ្វើរបាយការណ៍ ទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និងជាអ្នកសំរបសំរួលជាមួយក្រសួងយុត្តិធម៌ ។

**មាត្រា ២.-** លេខាធិការដ្ឋាន មានភារកិច្ចធ្វើជាសេនាធិការអោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការធ្វើអោយដំណើរការនៃប្រព័ន្ធតុលាការបានល្អប្រសើរ និងឯកភាពគ្នា ។

**មាត្រា ៣.-** លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដឹកនាំដោយលេខាធិការម្នាក់ និងលេខាធិការរង តាមការចាំបាច់ ។ លេខាធិការត្រូវជ្រើសតាំងសំរាប់អាណត្តិ ០៥ឆ្នាំ ក្នុងចំណោមសមាជិកជ្រើសតាំង ០៣នាក់ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំលើកទី១ របស់ខ្លួន ។ លេខាធិការរង ត្រូវជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រមដែលមានអតីតភាព យ៉ាងតិច ០៥ឆ្នាំ ។

លេខាធិការ ក្នុងការដឹកនាំបញ្ហាការងាររដ្ឋបាល នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសិទ្ធិចុះហត្ថលេខាលើលិខិត ឬ សេចក្តីសំរេចរដ្ឋបាល និងការងារផ្សេងៗទៀត ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រគល់អោយនាសម័យប្រជុំនីមួយៗ ។ លេខាធិការរងមានភារកិច្ចជួយលេខាធិការក្នុងការបំពេញការងារខាងលើ និងតាមការប្រគល់សិទ្ធិរបស់លេខាធិការ ។

**មាត្រា ៤.-** លេខាធិការ និងលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំរបស់សម័យប្រជុំ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ។ លេខាធិការមានឋានៈ និងបុព្វសិទ្ធិស្មើនឹង រដ្ឋលេខាធិការ ហើយលេខាធិការរង មានឋានៈ និងបុព្វសិទ្ធិស្មើនឹង អនុរដ្ឋលេខាធិការ ។

**មាត្រា ៥.-** លេខាធិការដ្ឋានត្រូវបែងចែកជា នាយកដ្ឋានជំនួយការកិច្ចការតុលាការ និងនាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ច ។ នាយកដ្ឋានទាំងពីរត្រូវបែងចែកជាការិយាល័យតាមការសំរេច នៃសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់លេខាធិការ ។

**មាត្រា ៦.-** នាយកដ្ឋានជំនួយការកិច្ចការតុលាការ ត្រូវដឹកនាំដោយប្រធានម្នាក់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹតក្នុងចំណោមចៅក្រមដែលមានសមត្ថភាព និងបទពិសោធណ៍តាមសំណើរបស់សម័យប្រជុំនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច ត្រូវតែងតាំងដោយព្រះរាជក្រឹត្យក្នុងចំណោមមន្ត្រី ដែលមានបទពិសោធន៍ផ្នែករដ្ឋបាល-ហិរញ្ញកិច្ច តាមសំណើរបស់សម័យប្រជុំនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

នាយកដ្ឋាននីមួយៗ មានអនុប្រធាន តាមការចាំបាច់ ដែលត្រូវតែងតាំងដោយសេចក្តីសំរេចរបស់សម័យប្រជុំ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។

**មាត្រា ៧.-** ថវិកាសំរាប់ដំណើរការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបែងចែកពីថវិការបស់ក្រសួងយុត្តិធម៌ ដោយរំលែកពីគំរោងចំណាយចែកជាផ្នែក ឬ ប្រការ តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាអាណាប័កដើមខ្សែ។ ចំណាយទាំងអស់ត្រូវធ្វើអាណត្តិបើកប្រាក់ដោយលេខាធិការ. គណនេយ្យករម្នាក់ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អោយទទួលបន្ទុកជាភ្នាក់ងារបើកផ្តល់។

**មាត្រា ៨.-** មន្ត្រីទាំងអស់នៃលេខាធិការដ្ឋាន ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជីក្នុងក្របខ័ណ្ឌ ឬ អាចជ្រើសរើសថ្មី។ បរិមាណនៃមន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ត្រូវកំណត់ក្នុងចំនួនអប្បរមាដែលអាចធ្វើទៅបាន។

**មាត្រា ៩.-** មន្ត្រីរាជការ នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ស្មើនឹងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

**មាត្រា ១០.-** កំណត់ហេតុទាំងអស់ និងឯកសារផ្សេងៗទៀត រួមទាំងឯកសាររបស់ក្រុមប្រឹក្សាវិន័យផង ត្រូវរក្សាទុកក្នុងលេខាធិការដ្ឋាន។ លេខាធិការធានាការបែងចែកឯកសារសម្ងាត់ទាំងឡាយ។

សមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានសិទ្ធិពិនិត្យឯកសារទាំងឡាយដែលរក្សាទុកនៅលេខាធិការដ្ឋាន។

## អន្តរបញ្ញត្តិ

**មាត្រា ១១.-** ក្នុងពេលដែលឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមមិនទាន់អាចរៀបចំថវិកាដោយខ្លួនឯងបាន ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរ៉ាប់រង ថវិកាចាំបាច់សំរាប់ដំណើរការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។

**មាត្រា ១២.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៤៤ អនក្រ.បក**

**ស្តីពី**

**ការកែសំរួលអត្រាពន្ធ និងអាករ លើទំនិញមួយចំនួន**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៩៦ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១ន ។ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤